# ប្រកាស

# ស្តីពី

# កាលបរិច្ឆេទផ្ញើរបាយការណ៍ របស់ធនាគារពាណិជ្ជ និងធនាគារឯកទេស

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញបទបញ្ជាលេខធ.៧៩៥-០២ បបជ ចុះថ្ងៃទី ៣០ ខែមិនា ឆ្នាំ១៩៩៥ ស្តីពីការផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជ
- បានឃើញសារាចរណែនាំលេខធ.៧៩៥-០២ សរណន ចុះថ្ងៃទី ៣១ ខែមិនា ឆ្នាំ១៩៩៥ ស្តីពីកាលបរិច្ឆេទនៃការផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជ មកធនាគារជាតិនៃកម្ពុជា
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៦

## ស ំ រេ ច

**ប្រការ ១.-**

ធនាគារពាណិជ្ជ និងធនាគារឯកទេស ត្រូវផ្ញើរាល់របាយការណ៍ប្រចាំគ្រាមកធនាគារជាតិនៃកម្ពុជា តាមកាលបរិច្ឆេទ ដូចបានកំណត់ខាងក្រោមៈ

- របាយការណ៍ប្រចាំថ្ងៃ ត្រូវផ្ញើមករៀងរាល់ពេលព្រឹក នៅថ្ងៃធ្វើការបន្ទាប់
- របាយការណ៍ប្រចាំសប្តាហ៍ ត្រូវផ្ញើមករៀងរាល់ថ្ងៃអង្គារ៍ នៃសប្តាហ៍បន្ទាប់
- របាយការណ៍ប្រចាំខែ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១០ នៃខែបន្ទាប់
- របាយការណ៍ប្រចាំត្រីមាស ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ ខែទីមួយនៃត្រីមាសបន្ទាប់
- របាយការណ៍ប្រចាំឆ្នាំ (របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យដោយស្នងការគណនីឯករាជ្យ) ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់
- របាយការណ៍ប្រាក់បំរុងកាតព្វកិច្ច ត្រូវផ្ញើមកតាមកាលបរិច្ឆេទនៃប្រតិទិន ដែលធនាគារជាតិនៃកម្ពុជាបានកំណត់និងចែកជូនតាមឆ្នាំនីមួយៗ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវផ្សព្វផ្សាយជាសាធារណៈ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា នៃឆ្នាំបន្ទាប់ ។

**ប្រការ ២.-**

ធនាគារពាណិជ្ជ និងធនាគារឯកទេស ត្រូវឆ្លើយតបរាល់លិខិតបទដ្ឋាន តាមកាលបរិច្ឆេទដែលធនាគារជាតិនៃកម្ពុជា កំណត់អោយឆ្លើយនិងអនុវត្ត ។

**ប្រការ ៣.-**

ធនាគារពាណិជ្ជ និងធនាគារឯកទេស ត្រូវបានអនុញ្ញាតអោយរាយការណ៍នៅថ្ងៃធ្វើការបន្ទាប់ ក្នុងករណីកាលបរិច្ឆេទដែលបានកំណត់ដូចមានចែងក្នុងប្រការ១ និងប្រការ២ខាងលើ ត្រូវចំថ្ងៃឈប់សំរាក ឬថ្ងៃបុណ្យជាតិ ។

**ប្រការ ៤.-**

ធនាគារពាណិជ្ជ និងធនាគារឯកទេស ដែលមិនបានអនុវត្តតាមប្រការ១ និងប្រការ២ខាងលើ ត្រូវរងការពិន័យតាមការកំណត់ ដូចខាងក្រោម ÷

ក- ចំពោះរបាយការណ៍:

| ចំនួនថ្ងៃដែលយឺតយ៉ាវ | ចំនួនទឹកប្រាក់និងរូបភាពពិន័យ |
|---|---|
| ▪ ចាប់ពី ១ ដល់ ៥ថ្ងៃ | ១.០០០.០០០ រៀល ក្នុង១ថ្ងៃ |
| ▪ ចាប់ពី ៦ ដល់ ១០ថ្ងៃ | ៧.៥០០.០០០ រៀល ក្នុង១ថ្ងៃ |
| ▪ ចាប់ពី ១១ ដល់ ១៥ថ្ងៃ | ១៥.០០០.០០០ រៀល ក្នុង១ថ្ងៃ |

ចាប់ពី១៦ថ្ងៃឡើងទៅ ធនាគារពាណិជ្ជ និងធនាគារឯកទេស ត្រូវរងបន្ថែមនូវការព្រមានជាលាយល័ក្ខអក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ ។

ខ- ចំពោះលិខិតឆ្លើយតប និងការផ្តល់ព័ត៌មានផ្សេងៗ:

| ចំនួនថ្ងៃដែលយឺតយ៉ាវ | ចំនួនទឹកប្រាក់និងរូបភាពពិន័យ |
|---|---|
| ▪ ចាប់ពី ១ ដល់ ៥ថ្ងៃ | ៥00.000 រៀល ក្នុង១ថ្ងៃ |
| ▪ ចាប់ពី ៦ ដល់ ១0ថ្ងៃ | ១.000.000 រៀល ក្នុង១ថ្ងៃ |

ចាប់ពី១១ថ្ងៃឡើងទៅ ធនាគារពាណិជ្ជ និងធនាគារឯកទេស ត្រូវរងបន្ថែមនូវការព្រមានជាលាយល័ក្ខអក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ ។

**ប្រការ ៥.-**

បទបញ្ជាលេខធ.៧៩៥-0២ បបជ ចុះថ្ងៃទី៣0 ខែមិនា ឆ្នាំ១៩៩៥ ស្តីពីការផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជ និងសារាចរណែនាំលេខធ.៧៩៥-0២ សរណន ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ១៩៩៥ ស្តីពីកាលបរិច្ឆេទនៃការផ្ញើរបាយការណ៍របស់ធនាគារពាណិជ្ជ មកធនាគារជាតិនៃកម្ពុជា ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៧.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២00៦

**ទេសាភិបាល**

**កន្លែងទទួល**

- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"